សារព័ត៌មាន

# ខ្មែរម្ចាស់ស្រុក

Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី ០២ លេខ ២៤៣ ចេញផ្សាយថ្ងៃ សៅរ៍ ទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៨

## សំជី ចាំង វ៉ាន់ថន ដូចបង្ហាញឱ្យឃើញថាសមត្ថកិច្ចតយ នៅតែចាញ់ចារមើពួកឈ្មួញរត់ពន្ធប្រេងសាំងដដែល



លោក ចាំង វ៉ាន់ថន



ទូកដឹកប្រេងសាំងគេចពន្ធនៅក្បែរព្រំដែនភ្នំដិន ខេត្តតាកែវ

ដោយ : ជ.ឧត្តម

ក្នុងមួយថ្ងៃៗមានអំពើរត់ពន្ធប្រេងសាំងរាប់ពាន់ រាប់ម៉ឺនលីត្របានហូរឆ្លងកាត់ច្រករបៀងតាមតំបន់ព្រំដែនភ្នំដិនក្នុងស្រុកគីរីវង្ស ខេត្តតាកែវ ។ ហើយបើយោងតាមប្រភពព័ត៌មានពីប្រជាពលរដ្ឋវិញ គេបានធ្វើការ

តទៅទំព័រ២ ស

## មេដឹកនាំអង្គការសមាគមខ្មែរកម្ពុជាក្រោមចំនួន៨រូប ស្នើសុំជួបឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក



លោក ថាច់ សេដ្ឋា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម



លោក ទឹម សាខន

ដោយ : ហង្ស ឧត្តម

មេដឹកនាំអង្គការសមាគមខ្មែរកម្ពុជាក្រោមចំនួន៨រូបដែលមជ្ឈដ្ឋានជាទូទៅធ្លាប់បានធ្វើការកត់សម្គាល់ថាជាអ្នកដឹកនាំឆ្នើមៗនោះបានស្នើសុំជួបជាមួយលោក John Negroponte ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេស

តទៅទំព័រ២ ខ

## អំពើពុករលួយគ្រប់ប្រភេទនឹងត្រូវរាតត្បាតកម្ពុជារយៈពេល៥ឆ្នាំទៀត



លោកស្រី យូ អយ



លោក អ៊ឹង ប៊ុនហូវ

ដោយ : រតនៈ

លទ្ធផលជាផ្លូវការ នៃការបោះឆ្នោតជាតិ អាណត្តិទី៤ នេះបង្ហាញថា គណបក្សប្រជាជនលោក*ហ៊ុន សែន* លួចបន្លំសន្លឹកឆ្នោតបានច្រើនលើសលប់រហូតអាចបង្កើតរាជរដ្ឋាភិបាលម្នាក់ឯង ។ លទ្ធផលនេះ

តទៅទំព័រ៣ គ

## ព្រះមហាក្សត្រឆ្លើយតបនៅពេលអ្នកតំណាងរាស្ត្រ គណបក្ស សម រង្ស៊ី រក្សាជំហរដដែល



លោក សម រង្ស៊ី



លោកស្រី មូរ សុខហួរ



លោក ម៉ៅ មុនីវណ្ណ



លោកស្រី ពត ពៅ



លោក យន្ត ថារ៉ូ



លោក ឡុង រី



លោក ចាន់ ចេង



លោកស្រី កែ សុវណ្ណរតន៍

ដោយ : ស្សាទរីយ៍

ព្រះមហាក្សត្រ ព្រះបរមនាថ *នរោត្តម សីហមុនី* បានឆ្លើយតប នឹងសំណើសុំពន្យារពេល របស់អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ដើម្បីចូលស្បថកាន់តំណែង ដាច់ដោយឡែក ពីអ្នកតំណាងរាស្ត្រចោរ តំណាងរាស្ត្រយួន និងតំណាងរាស្ត្រខ្មោចហើយ ។ ចម្លើយរបស់ព្រះមហាក្សត្រនេះ បាន

តទៅទំព័រ៤ ម

## អគ្គលេខាធិការរដ្ឋសភាស្នើ ស ខេង ចាត់វិធានការ ហ៊ុន តូ ដែលពាក់ព័ន្ធនឹងករណីវាយតប់តំណាងរាស្ត្រ នួន រ៉ុទ្ធី



លោក នួន រ៉ុទ្ធី អតីតអ្នកតំណាងមណ្ឌលកំពង់ចាម



លោក ស ខេង



លោក ឡេង ប៉េងឡុង

ដោយ : សច្ចះ

លោក*ឡេង ប៉េងឡុង* អគ្គលេខាធិការរដ្ឋសភា បានស្នើលោក*ស ខេង* ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី កសួងមហាផ្ទៃ ធ្វើការស្រាវជ្រាវអំពីករណី រំលោភអភ័យឯកសិទ្ធិលោក*នួន រ៉ុទ្ធី* សមាជិកសភាគណបក្សសម រង្ស៊ី មណ្ឌលកំពង់ចាម ។

លិខិតលោក*ឡេងប៉េងឡុង*

តទៅទំព័រ៤ ន

## អំណាចគណបក្សប្រជាជន ហ៊ុន សែន ពង្រាបតែខ្មែរឱ្យលុតជង្គង់នៅចំពោះមុខសៀម



លោក ហ៊ុន សែន



សកម្មភាពទាហានឈុតខ្មៅ និងទាហានជាំវ៉ាសៀមកំពុងលុកលុយក្នុងបូរណភាពទឹកដីនៃប្រទេសកម្ពុជា

ដោយ : គ.អរពិន្ទ

ហេតុអ្វីបានជាទាហានសៀមតែ១២នាក់ហ៊ានបំពានឆ្លងដែនហូរចូលកាត់ជួរទាហានខ្មែរទៅចូលក្នុងប្រាសាទតាក្របីនៅលើទឹកដីខ្មែរ ទាំងមានទាហានខ្មែរឈរជើងយាមប្រចាំការនៅទីនោះកាលពីពេលថ្មីៗនេះ ? ហេតុការណ៍នោះគឺនៅវេលាល្ងាចនៃថ្ងៃពុធ ទី១០ ខែកញ្ញា ទាហានសៀមឈុតខ្មៅបាននាំ

តទៅទំព័រ៤ ខ

*ទស្សនៈមិត្តអ្នកអាន*

## ភ្លូកទឹកភ្លូកដី

**ក.ក.ន៖** ការិយាល័យនិពន្ធសារព័ត៌មាន "*ខ្មែរម្ចាស់ស្រុក*" ទើបបានទទួលលិខិតមួយច្បាប់របស់ប្រិយមិត្តអ្នកអានកាលពីម្សិលមិញនេះ។ លិខិតរបស់ប្រិយមិត្តអ្នកអានយើងលើកនេះមានចំណងជើងថា "*ភ្លូកទឹក ភ្លូកដី*"។

ដូច្នេះដើម្បីជនរួមជាតិបានយល់ច្បាស់អំពីខ្លឹមសារ*ភ្លូកទឹក ភ្លូកដី* នេះ ការិយាល័យនិពន្ធយើងនឹងធ្វើការចុះផ្សាយតាមខ្លឹមសារដើមទាំងស្រុងដោយមិនចាំបាច់ធ្វើការអធិប្បាយអ្វីបន្ថែមឡើយ។

តទៅទំព័រ២ ហ

## ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លីម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្ទំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្តី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់ឆ្អល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្បែត ព្យាបាល យ៉ាងស័ក្តិសិទ្ធិ។

- មានបន្ទប់បុរស ស្ត្រី ដាច់ដោយឡែកពីគ្នា
- មានលក់ថ្នាំសម្រាប់ព្យាបាលដោយខ្លួនឯង

ទីតាំងផ្ទះលេខ០៧៧ **ហោ លីម ថែសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្អាតចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : 012 363 331, 016 719 616,

*បរិយាយថ្ងៃនេះ*

## ចាំស្តាប់របាយការណ៍អឺរ៉ុបស្តីពីការបោះឆ្នោតនៅកម្ពុជាដែលនឹងចេញផ្សាយនៅខែតុលា

ដោយ : ហង្ស ច្រាថ្លា

តំណាលគ្នានឹងការបន្តយុទ្ធនាការនៃលោកប្រធាន សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងដ៏ធំ រួមដំណើរដោយលោកកឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្សបន្តការតវ៉ានៅលើឆាកអន្តរជាតិដូចកំពុងប្រព្រឹត្តបច្ចុប្បន្ននៅសហភាពអឺរ៉ុបរកការសុំឱ្យរដ្ឋាភិបាលប្រទេសនានាពិនិត្យដល់គំនិតស៊ីជម្រៅនូវភស្តុតាងជាក់ស្តែងនៃការលួចបន្លំប្លន់សន្លឹកឆ្នោតដោយ

តទៅទំព័រ៤ ក

**តមកពីទំព័រ១ ខ**

សហរដ្ឋអាមេរិកនៅអំឡុងសប្ដាហ៍នេះដើម្បីពិភាក្សាអំពីការរំលោភសិទ្ធិខ្មែរក្រោមក្នុងប្រទេសកម្ពុជានិងនៅក្នុងប្រទេសយួន។

នៅក្នុងលិខិតផ្ញើជូនស្ថានទូតអាមេរិកកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ លោក *ថាច់ សេដ្ឋា* ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមបានសរសេររៀបរាប់ថា លោកមានបំណងដឹកនាំគណៈប្រតិភូមួយក្រុមដែលមានតំណាងមកពីសមាគមសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម និងសមាគមព្រះពុទ្ធសាសនាខ្មែរកម្ពុជាក្រោមដើម្បីជួបពិភាក្សាជាមួយលោកឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកខណៈពេលដែលលោកមកបំពេញទស្សនកិច្ចជាផ្លូវការនៅកម្ពុជាក្នុងពេលដ៏ខ្លីខាងមុខនេះ។

លោក *ថាច់ សេដ្ឋា* បានបន្តទៀតថា "*គណៈប្រតិភូនឹងដាក់ជូនលោក John Negroponte នូវរបាយការណ៍មួយចំនួនដែលបង្ហាញពីការរំលោភសិទ្ធិមនុស្សយ៉ាងច្រើនលើជនជាតិភាគតិចខ្មែរក្រោមក្នុងប្រទេសវៀតណាម និងក្នុងប្រទេសកម្ពុជា*"។

គេអាចកាត់យល់បានថា ករណីត្រង់ចំណុចនេះគឺជាករណីលោក *ទឹម សាខន* អតីតព្រះចៅអធិការវត្តភ្នំដិនខាងជើង ដែលត្រូវអាជ្ញាធរខ្មែរចាប់ផ្សឹករួចបញ្ជូនខ្លួនលោកទៅឱ្យអាជ្ញាធរយួនដាក់គុកនៅឯស្រុកយួន។

មិនតែប៉ុណ្ណោះនៅពេលដែលអាជ្ញាធរយួនប្រកាសថាដោះលែងលោក *ទឹម សាខន* ឱ្យមានសេរីភាពវិញហើយ តែបែរជាមានសេចក្ដីរាយការណ៍ថា លោក *ទឹម សាខន* ត្រូវអាជ្ញាធរយួនឃុំក្នុងផ្ទះមិនឱ្យលោកមានសេរីភាពនោះ ក៏ជាចំណុចដែលលោក *ថាច់ សេដ្ឋា* ត្រូវលើកឡើងផងដែរ។

លោក *ថាច់ សេដ្ឋា* ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមបានថ្លែងឱ្យដឹងថា "*យើងនឹងដាក់ជូនលោក John Negroponte នូវរបាយការណ៍របស់យើង ហើយជម្រុញឱ្យសហរដ្ឋអាមេរិកគាបសង្កត់រដ្ឋាភិបាលឱ្យគោរពសិទ្ធិសេរីភាពរបស់យើងខាងការបញ្ចេញមតិផ្នែកសាសនា និងបញ្ឈប់ការរឹបអូសយកដីធ្លីរបស់យើង*"។

លោក *ចន ចនសុន* អ្នកនាំពាក្យស្ថានទូតអាមេរិកប្រចាំកម្ពុជាបាននិយាយកាលពីថ្ងៃព្រហស្បតិ៍កន្លងទៅថា ស្ថានទូតពិតជាបានទទួលលិខិតរបស់គណៈប្រតិភូនេះមែនហើយ។ ប៉ុន្តែមិនទាន់បានសម្រេចពីគម្រោងពេញលេញនៃដំណើរទស្សនកិច្ចរបស់លោក John Negroponte នៅឡើយទេ ដែលដំណើរទស្សនកិច្ចនេះនឹងប្រព្រឹត្តទៅពីថ្ងៃអាទិត្យ ទី១៤ ខែកញ្ញា ដល់ថ្ងៃអង្គារ ទី១៦ ខែកញ្ញា ឆ្នាំ២០០៨។

គួរបញ្ជាក់ថាគ្រាន់តែករណីអតីតព្រះសង្ឃ *ទឹម សាខន* ដែលត្រូវបានអាជ្ញាធរខ្មែរចាប់លោកផ្សឹកយ៉ាងតក់ក្រហល់រួចបញ្ជូនលោកទៅឱ្យតុលាការយួនកាត់ទោសលោកដាក់គុកនៅស្រុកយួននោះ គឺធ្វើឱ្យមានការភ្ញាក់ផ្អើលពេញពិភពលោកទៅហើយ ដោយសារលេចចេញនូវការតវ៉ាយ៉ាងខ្លាំងក្លាបំផុត។

ប៉ុន្តែអាជ្ញាធរយួននៅតែធ្វើមិនដឹងមិនឮដដែល ហើយបន្តឃុំខ្លួនលោក *ទឹម សាខន* ក្នុងផ្ទះរហូតមកដល់សព្វថ្ងៃនេះ ទោះបីជាលោកបានជាប់គុករយៈពេល១ឆ្នាំតាមការកំណត់ដោយតុលាការយួនហើយក៏ដោយ។

មជ្ឈដ្ឋានជាទូទៅរំពឹងថា លោកឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកនឹងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងជាមិនខាន ប្រសិនបើបានមើលនូវរបាយការណ៍របស់អង្គការសមាគមខ្មែរកម្ពុជាក្រោមដែលដាក់ជូនលោកនោះ។ហើយចំណាត់ការណាមួយនឹងត្រូវកើតយ៉ាងពិតប្រាកដ ព្រោះបញ្ហាខ្មែរកម្ពុជាក្រោមនេះជាបញ្ហាជិតដាមទៅដោយឈាមដែលសហរដ្ឋអាមេរិកមិនអាចមើលរំលងបានជាដាច់ខាត។

ប៉ុន្តែឧត្តមសេនីយ៍ឯក *ខៀវ សុភ័គ* អ្នកនាំពាក្យក្រសួងមហាផ្ទៃត្រូវបាន The Cambodia Daily ដកស្រង់សម្ដីលោកយកមកផ្សាយថា "*ពាក្យបណ្ដឹងរបស់សមាគមខ្មែរក្រោមមួយចំនួនគឺដោយសារតែពួកគេមានការពាក់ព័ន្ធនឹងគណបក្សប្រឆាំង*"។

យ៉ាងណាក៏ដោយ លោក *ថាច់ សេដ្ឋា* ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមនៅតែអះអាងយ៉ាងម៉ឺងម៉ាត់ថា "*យើងនឹងដាក់ជូនលោកឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកនូវរបាយការណ៍របស់យើង និងជម្រុញយ៉ាងសកម្មឱ្យសហរដ្ឋអាមេរិកដាក់ការគាបសង្កត់ទៅលើរដ្ឋាភិបាលឱ្យគោរពសិទ្ធិសេរីភាពពួកយើងដែលជាខ្មែរកម្ពុជាក្រោម ហើយទាមទារឱ្យរដ្ឋាភិបាលយួនបញ្ឈប់ការរឹបអូសយកដីធ្លីរបស់ពួកយើងដែលជាខ្មែរកម្ពុជាក្រោមថែមទៀតផង*"៕

**តមកពីទំព័រ១ ហ**

គណបក្សប្រជាជនកម្ពុជាជាគណបក្សមួយដែលមានប្រវត្តិជាគណបក្សកុម្មុយនីស្តនៅកម្ពុជា។ ក្រោយពីមនុស្សខ្លះដែលជាសមាជិកបក្សនេះបានទៅហៅយួនឱ្យលើកទ័ពមកកំចាត់ ប៉ុល ពតមក គណបក្សនេះបានក្លាយជាបក្សដឹកនាំប្រទេសរហូតដល់ឆ្នាំ១៩៩១។

បន្ទាប់ពីបោះឆ្នោតជាតិលើកទី១ ដែលរៀបចំឡើងដោយអន្តរជាតិ គណបក្សនេះបានចាញ់ឆ្នោតយ៉ាងអាម៉ាស់ ។ប៉ុន្តែសារជាតិកុម្មុយនីស្តគឺតែងតែប្រើអំណាចផ្ដាច់ការដើម្បីការពារអំណាចរបស់ពួកគេ ដូច្នេះគេបានបង្កើតជាតំបន់អបគមន៍ដើម្បីឡាំបាស្រវាអំណាចវិញ។

ដោយមិនប្រគល់ឱ្យអន្តរជាតិដោះស្រាយបន្តអ្នកនយោបាយខ្មែរបានលង់ នឹងឧបាយកលរបស់ពួកកុម្មុយនីស្តដោយរៀបចំឱ្យមានជា *សហនាយករដ្ឋ*មន្ត្រីដែលជារូបមន្តដ៏សែនអាក្រក់និងមិនដែលមានលើសកលលោក។ ប្រជាពលរដ្ឋខ្មែរចាប់ផ្ដើមស្រងាកចិត្តចំពោះរូបមន្តនោះ ព្រោះជារូបមន្តដែលធ្វើឱ្យខ្លាដែលកំពុងតែបាក់ចង្កូមហើយនោះអាចនឹងខាំត្របាក់វិញបាន។

មិនខុសពីការគិតរបស់ពលរដ្ឋខ្មែរមែន ព្រោះពីមួយថ្ងៃទៅមួយថ្ងៃក្រុមកុម្មុយនីស្តនេះបានពង្រឹងអំណាចដែលមានស្រាប់និងចាប់ផ្ដើមអនុវត្តយុទ្ធសាស្ត្រកំចាត់ទាំងក្ដៅនិងត្រជាក់ចំពោះក្រុមអ្នកតស៊ូដែលកាន់អំណាចរួមគ្នាជាមួយពួកគេ។

ដោយសារតែភាពទន់ខ្សោយអំណួតពុករលួយបក្ខពួកនិយម និងភាពជោរនឹងអំណាច ហើយកំចាត់មន្ត្រីល្អៗដូចជាលោក*សម រង្ស៊ី* ជាដើមរបស់ទ្រង់ *រណឫទ្ធិ* ទីបំផុតក្រុមកុម្មុយនីស្ត ក៏ដណ្ដើមបានអំណាចយោធាទាំងស្រុងនៅក្នុងរដ្ឋប្រហារបង្ហូរឈាមខ្មែរនៅខែកក្កដាឆ្នាំ១៩៩៧។

ការបោះឆ្នោតជាតិលើកទី២ ឆ្នាំ ១៩៩៨ លើកទី៣ ឆ្នាំ ២០០៣ លើកទី៤ ឆ្នាំ ២០០៨ ត្រូវបានត្រួតត្រាទាំងស្រុងដោយគណបក្សប្រជាជន។

ដូច្នេះយើងអាចយល់បានហើយថាតើក្រុមដែលស្រឡាញ់អំណាចហើយមានអតីតភាពជនកុម្មុយនីស្តទាំងឡាយជាមេដឹកនាំនោះសុខចិត្តឱ្យក្រុមរបស់ខ្លួនបាត់បង់អំណាចទេ?ចម្លើយគឺទេ។ បើទេ សួរថាតើការបោះឆ្នោតមានយុត្តិធម៌ទេ? ។ចម្លើយគឺប្រាកដជាអត់យុត្តិធម៌ហើយ។

ជាទិដ្ឋភាពរួមនៅប្រទេសកម្ពុជាអំណាចទាំងអស់គឺរបស់គណបក្សប្រជាជនទាំងអស់ដូចជាអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិតុលាការ ។ហើយបើនិយាយពីប្រព័ន្ធផ្សព្វផ្សាយវិទ្យុ និងទូរទស្សន៍ទាំងអស់ជា របស់គណបក្សប្រជាជននិងជារបស់អ្នកដែលគាំទ្រគណបក្សប្រជាជន ទោះជាមិនចង់គាំទ្រក៏ត្រូវតែគាំទ្រ ។ឯកងទ័ពនិងប៉ូលិសក៏ជារបស់គណបក្សប្រជាជន។ ចំណែកអ្នកកាន់លុយជាតិក៏ជារបស់គណបក្សប្រជាជន។ បើងាកមកអ្នករៀបចំការបោះឆ្នោតវិញគឺ គ.ជ.ប ជា គ.ប.ជ មានន័យថា គ.ជ.ប ជាគណបក្សប្រជាជនដូច្នេះហើយបានជាគណបក្សប្រជាជនអាចហៅយួនមកបោះឆ្នោតឱ្យយ៉ាងភ្លូកទឹកភ្លូកដី។

គណបក្សប្រជាជនអាចដាស់ខ្មោចឱ្យបោះឆ្នោតឱ្យយ៉ាងភ្លូកទឹកភ្លូកដី ។គណបក្សប្រជាជនអាចបញ្ជាឱ្យមេភូមិ មេឃុំចេញ ទំរង់ ១០១៨ ឱ្យអ្នកដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សំរាប់បោះឆ្នោត។ បោះឆ្នោតឱ្យយ៉ាងភ្លូកទឹកភ្លូកដី ។គណបក្សប្រជាជនអាចបញ្ជាឱ្យ គ.ជ.ប លុបឈ្មោះអ្នកគាំទ្រគណបក្សប្រឆាំងបានយ៉ាងភ្លូកទឹកភ្លូកដី ។គណបក្សប្រជាជនអាចលួចលុយជាតិហើយយកទៅទិញទឹកចិត្តអ្នកបោះឆ្នោតយ៉ាងភ្លូកទឹកភ្លូកដី។ គណបក្សប្រជាជនអាចគំរាមអ្នកមិនគាំទ្រខ្លួនបានយ៉ាងភ្លូកទឹកភ្លូកដី។

គណបក្សប្រជាជនអាចប្រើប្រព័ន្ធឃោសនាម្នាក់ឯងបានយ៉ាងភ្លូកទឹកភ្លូកដី ។ងាកទៅក្រុមប្រឹក្សាធម្មនុញ្ញមានប្រធានជាសមាជិកគណបក្សប្រជាជន ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញជាគណបក្សប្រជាជន។ ដូច្នេះហើយបានជាក្រុមប្រឹក្សាធម្មនុញ្ញគណបក្សប្រជាជនបដិសេធពាក្យបណ្ដឹងរបស់គណបក្សប្រឆាំងបានយ៉ាងភ្លូកទឹកភ្លូកដី។

សរុបមកគេអាចនិយាយបានថា គណបក្សប្រជាជននិងភ្លូកទឹកភ្លូកដីគឺតែ១ គឺថា ប្រើអំណាចផ្ដាច់ការបានយ៉ាងភ្លូកទឹកភ្លូកដី ។រំលោភសិទ្ធិមនុស្សបានយ៉ាងភ្លូកទឹកភ្លូកដី។ ពុករលួយយ៉ាងភ្លូកទឹកភ្លូកដី។ កាប់បំផ្លាញព្រៃឈើយ៉ាងភ្លូកទឹកភ្លូកដី ។អយុត្តិធម៌សង្គមយ៉ាងភ្លូកទឹកភ្លូកដី។ លួចនិងលក់សម្បត្តិជាតិយ៉ាងភ្លូកទឹកភ្លូកដី ។យួននិងសៀមឈ្លានពានទឹកដីយ៉ាងភ្លូកទឹកភ្លូកដី។ យួនចូលស្រុកយ៉ាងភ្លូកទឹកភ្លូកដី។ លួចសន្លឹកឆ្នោតយ៉ាងភ្លូកទឹកភ្លូកដី។ ហើយអ្វីដែលគួរឱ្យចង់ឈឺសើចនោះគឺសូម្បីតែសំលេងគាំទ្រគណបក្សប្រឆាំងដ៏ថ្លៃថ្នូរដែលសល់ពីការលួចបន្លំចំនួន ២៩កៅអីក៏គណបក្សប្រជាជនកម្ពុជាប្រកាសចង់ប្លន់យកយ៉ាងភ្លូកទឹកភ្លូកដីដែរ៕

**តមកពីទំព័រ១ ស**

ឆ្លុះបញ្ចាំងឱ្យឃើញថា ប្រការដែលកើតមានអំពើរត់ពន្ធប្រេងសាំងទាំងយប់ទាំងថ្ងៃយ៉ាងគគ្រឹកគគ្រេងបែបនេះគឺបណ្ដាលមកពីការឃុបឃិតគ្នារវាងអាជ្ញាធរមានសមត្ថកិច្ច និងឈ្មួញរកស៊ីរត់ពន្ធប្រេងសាំង។

ប៉ុន្តែបើតាមសម្ដីលោកមេគយ *ប៉ាង វ៉ាន់ថន* នៅភ្នំដិនវិញលោកបែរជានិយាយប្រាប់បណ្ដាញព័ត៌មានថា "*ប្រជាពលរដ្ឋនៅទីនេះខ្លាំងណាស់, ពួកគេមិនសូវកោតញញើតច្បាប់ និងកោតញញើតសមត្ថកិច្ចគយទេ។ យើងមានការលំបាកខ្លាំងណាស់ចំពោះការបង្រ្កាបប្រេងសាំងគេចពន្ធនៅទីនេះ ព្រោះថា កម្លាំងគយរបស់យើងតែងតែជួបប្រទះនូវការតបតពីឈ្មួញរកស៊ីរត់ពន្ធប្រេងសាំងរហូតដល់មានមន្ត្រីគយរបស់យើងម្នាក់ត្រូវរងរបួសយ៉ាងដំណំដោយសារពួកឈ្មួញរត់ពន្ធប្រេងសាំងវាយបែកក្បាល*"។

មេគយភ្នំដិនឈ្មោះ *ប៉ាង វ៉ាន់ថន* បានបន្តទៀតថា "*ទោះបីជាមានការតបតពីឈ្មួញយ៉ាងណាក៏ដោយ ក៏មន្ត្រីគយរបស់យើងនៅតែព្យាយាមយ៉ាងសកម្មក្នុងការបង្រ្កាបបទល្មើសនេះ។ ប៉ុន្តែបើឱ្យយើងបង្រ្កាបករណីរត់ពន្ធប្រេងសាំងឱ្យអស់នោះ គឺមិនអាចទៅរួចទេព្រោះឈ្មួញរកស៊ីរត់ពន្ធប្រេងសាំងនេះមានច្រើនណាស់ ឯកម្លាំងគយយើងវិញមានចំនួនតិចតួចប៉ុណ្ណោះ ដែលធ្វើឱ្យការរត់ពន្ធប្រេងសាំងនៅតែកើតមានឥតឈប់ឈរ*"។

សំដីលោក *ប៉ាង វ៉ាន់ថន* ម្នាក់នេះហាក់បានសារភាពលើកទង់ជ័យសរួចស្រេចទៅហើយថា សមត្ថកិច្ចគយពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទប់ស្កាត់និងបង្រ្កាបអំពើរត់ពន្ធប្រេងសាំងខុសច្បាប់នៅតំបន់ភ្នំដិននោះទេ។

មិនតែប៉ុណ្ណោះមានមន្ត្រីគយខ្លះបានអះអាងយ៉ាងកំសោយថា "*ដោយសារតែតំបន់ព្រំដែនភ្នំដិន របស់ស្រុកគីរីវង្ស ខេត្តតាកែវ ជាប់នឹងព្រំប្រទល់ដែនខេត្តអានយ៉ាងប្រទេសយួន ដែលមានវាលលិចទឹកល្ហល្ហាចជុំវិញច្រកទ្វារអន្តរជាតិភ្នំដិន ទើបធ្វើឱ្យមានលក្ខណៈអំណោយផលដល់ពួកឈ្មួញរកស៊ីរត់ពន្ធប្រេងសាំងនោះ ជាពិសេសនៅក្នុងរដូវវស្សានេះតែម្ដង*"។

តាមពិតទៅនៅតំបន់ភ្នំដិនមួយនេះ ការរត់ពន្ធប្រេងសាំងដោយពួកឈ្មួញខិលខូចគឺមានទាំងរដូវវស្សា និងរដូវប្រាំងគ្មានខកខាននៅរដូវណាមួយនោះទេ ។ហើយអ្វីដែលថា អ្នករកស៊ីរត់ពន្ធប្រេងសាំងមានច្រើនពេក មិនអាចបង្រ្កាបអស់នោះ ក៏ជាលេសមួយដើម្បីបិទបាំងពីភាពកំសោយរបស់លោក *ប៉ាង វ៉ាន់ថន* ប៉ុណ្ណោះ។

លោកមេគយ *ប៉ាង វ៉ាន់ថន* បានអួតប្រាប់បណ្ដាញព័ត៌មានក្នុងស្រុកមួយថា "*ការបង្រ្កាបអំពើរត់ពន្ធប្រេងសាំងរាល់ថ្ងៃនេះគឺជាការបង្រ្កាបតាមរបៀបភ្លៀងរលឹម*" Sic! ។

លោកមេគយភ្នំដិនម្នាក់នេះបានបន្តទៀតថា យើងបានចាត់តាំងបណ្ដាញរបស់យើងដោយយើងបានជួយឧបត្ថម្ភថវិកាដល់ពួកគេដើម្បីឱ្យពួកគេជួយផ្ដល់ព័ត៌មានឱ្យយើង។ ចំណែកពួកឈ្មួញរកស៊ីរត់ពន្ធប្រេងសាំងវិញ ក៏មានបណ្ដាញតាមឃ្លាំមើលសកម្មភាពរបស់យើងដែរ។

លោក *ប៉ាង វ៉ាន់ថន* បានសម្ដែងនូវអំណួតនៃការបង្រ្កាបមួយបែបដោយលោកបានអះអាងយ៉ាងដូច្នេះថា "*រថយន្តរបស់យើងតាមមិនទាន់រថយន្តដឹកប្រេងគេចពន្ធរបស់ឈ្មួញទេ តែអ្វីដែលពួកឈ្មួញខ្លាចគយយើងនោះ គឺយើងវាយដែកគោលប្រវែងជាងមួយតឹកភ្ជាប់ទៅនឹងក្ដារបន្ទះដើម្បីចាំបោះចូលកង់រថយន្តរត់ពន្ធប្រេងសាំងទាំងនោះ ។ជួនកាលកង់រថយន្តជនល្មើសធ្លាយហើយ តែគេអាចបើកគេចពីសមត្ថកិច្ចគយបានចម្ងាយដល់ទៅ១០ប្លាយគីឡូម៉ែត្រទៀតឯណោះ*"។

លោក *ប៉ាង វ៉ាន់ថន* បានសារភាពថា នៅចំណុចភូមិព្រៃតាម៉ៅ និងភូមិពោធិ៍ខ្វិត ស្ថិតក្នុងឃុំភ្នំដិន ស្រុកគីរីវង្សនេះដែរ គឺកម្លាំងគយរបស់លោកមិនអាចចូលចុះទេ ព្រោះអ្នករកស៊ីប្រេងសាំងគេចពន្ធនៅទីនោះគេចងសម្ព័ន្ធភាពគ្នារឹងមាំណាស់ ។ ហើយនៅតាមទូកដឹកប្រេងសាំងគេចពន្ធពួកឈ្មួញមានសុទ្ធតែច្បូកមុខ៣, កាំបិត, ពូថៅ ហើយអាចមានដល់ទឹកអាស៊ីតទៀតដែលពួកគេទាំងនេះមិនខ្លាចប្រឈមតតាំងជាមួយនឹងសមត្ថកិច្ចគយព្រមទាំងប៉េអឹមឡើយ។

នេះគ្រាន់តែជាសម្ដីរបស់លោកមេគយភ្នំដិនតែម្ខាងប៉ុណ្ណោះ។ ឥឡូវយើងគួរពិចារណាអំពីពាក្យសម្ដីរបស់ឈ្មួញរកស៊ីរត់ពន្ធប្រេងសាំងម្ដងវិញ តើគេមានផលវិបាកអ្វីខ្លះ រហូតដល់ថ្នាក់ហ៊ានរកស៊ីខុសច្បាប់បែបនេះ ?

ស្ត្រីម្នាក់ដែលគេស្គាល់ថាជាអ្នករកស៊ីប្រេងសាំងគេចពន្ធបានអធិប្បាយថា "*ខ្ញុំទើបនឹងរកស៊ីដឹកសាំងគេចពន្ធនេះបានតែជាងមួយខែប៉ុណ្ណោះ។ខ្ញុំមិនមានមុខរបរអ្វីផ្សេងទៀតនោះទេ ហើយបើខ្ញុំមិនឆ្លៀតរកស៊ីបែបនេះ គឺខ្ញុំមិនមានអ្វីដើម្បីចិញ្ចឹមក្រពះឡើយ*"។

លោក *ប៉ាង វ៉ាន់ថន* បានគូសបញ្ជាក់ថា តាមផ្លូវច្រកទ្វារអន្តរជាតិភ្នំដិននេះមិនសូវមានអ្នករកស៊ីប្រេងសាំងគេចពន្ធហ៊ានឆ្លងកាត់ទេ ពោលគឺច្រើនតែនៅតាមច្រករបៀងដែលមិនមានកម្លាំងគយប្រចាំការនៅទីនោះ។

បញ្ហាខ្វះខាតកម្លាំងដាក់តាមច្រករបៀងនេះយើងយល់ថា ជាកំហុសរបស់លោក *ប៉ាង វ៉ាន់ថន* ខ្លួនឯងទេ។ ព្រោះបើដឹងថាខ្វះកម្លាំងហើយ ម៉េចក៏មិនស្នើសុំកម្លាំងបន្ថែមទៅទីចាត់ការគយធំ ? ឬមួយខ្លាចបានកម្លាំងបន្ថែមដាក់នៅតាមច្រករបៀងទាំងឡាយទាំងពួងហ្នឹងទៅ វ៉ារលាយរលត់អស់លាភសក្ការៈ ?

យើងមិនហ៊ានចោទប្រកាន់ទៅលើលោកមេគយភ្នំដិនថាជាបុគ្គលបិទភ្នែកម្ខាង បើកភ្នែកម្ខាង ឬជាត្រីងៀតឆ្អៀតពង ឬស្សីក្នុងស៊ងឆ្អៀតដុះទំពាំងនោះទេ តែប្រជាពលរដ្ឋដែលរស់នៅទីនោះបាននិយាយពេញៗមាត់ថាអំពើរត់ពន្ធប្រេងសាំងពីស្រុកយួនមកនេះបើមិនមានការបើកដៃពីសមត្ថកិច្ចគយ ប៉ូលិស ប៉េអឹមទេ គឺមិនអាចហូរចូលស្រុកខ្មែរដូចទឹកបាក់ទំនប់បានឡើយ។

យើងនៅចាំបានថា កាលពីជំនាន់លោក *សម រង្ស៊ី* ធ្វើជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលោកបានដឹកនាំកម្លាំងមន្ត្រីគយចុះបង្រ្កាបទំនិញគេចពន្ធដោយផ្ទាល់ដើម្បីប្រមូលប្រាក់ពន្ធយកទៅបង្កើនថវិកាចំណូលរបស់ជាតិ។

ប៉ុន្តែបើពិនិត្យមើលពីចំណាត់ការរបស់លោក *គាត ឈន់* ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រោយនេះវិញ គឺដូចឱ្យពួកអ្នករកស៊ីរត់ពន្ធរកស៊ីមានបានធ្វើជាមហាសេដ្ឋីគ្រប់ៗគ្នាទៅហើយ។ នេះមកពីលោក*គាត ឈន់* នៃគណបក្សប្រជាជន *ហ៊ុន សែន* អសមត្ថភាពពេក ទើបលោកមេគយធំ *ប៉ែន ស៊ីម៉ន* ចេះតែត្រជាក់ល្ហឹមនឹងអំពើពុករលួយយ៉ាងរីករាលដាលក្នុងស្ថាប័នគយ និងរដ្ឋាករនោះ៕

**តមកពីទំព័រ១ គ**

នឹងធ្វើឱ្យកម្ពុជា ពន្យារពេលបង្កើតច្បាប់ ប្រឆាំងអំពើពុករលួយ៥ឆ្នាំទៀត, ហើយឈ្មួញនិងមន្ត្រីខិលខូចធ្លាប់ធ្វើបាបប្រជារាស្ត្រកន្លងមក ដូចជាអ្នកស្រី*យូ អយ* រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជន និងមេឈ្មួញ*ស៊ុយសុផាន* មានឱកាសធ្វើបាបរាស្ត្រម្ចាស់ដី យ៉ាងសាហាវដូច៥ឆ្នាំមុនទៀត ។

លទ្ធផល នៃការកេងបន្លំសន្លឹកឆ្នោតនេះ ក៏បើកឱកាសឱ្យលោក*អ៊ឹង ប៊ុនហូវ* ប្រធានក្រុមហ៊ុន AZ និងជាសមាជិកសភាគណបក្សប្រជាជន នៅមណ្ឌលតាកែវមានឱកាសជិះតទារប្រាក់ ពីអ្នកធ្វើដំណើរលើផ្លូវជាតិលេខ៤ ពីភ្នំពេញ ទៅក្រុងព្រះសីហនុចំនួន៥ឆ្នាំទៀតដែរ ។

អ្នកស្រី*យូ អយ* ដែលមានប្រវត្តិដ៏ក្លាហាន បញ្ជាទាហានកងទ័ពឆ័ត្រយោង នៃកងពល៩១១អោយបាញ់ប្រជាពលរដ្ឋចាប់ប្រជាពលរដ្ឋ និងបំផ្លាញលំនៅឋានប្រជាពលរដ្ឋ នៅឯខេត្តកំពង់ស្ពឺ កាលពីប៉ុន្មានឆ្នាំមុននោះ មិនញញើតនឹងបន្តនូវអំពើហិង្សារបស់គាត់ ទៅលើប្រជាពលរដ្ឋទៀតដែរ ។

អ្នកស្រី*យូ អយ* ដែលអ្នកតំណាងរាស្ត្រ គណបក្សសមរង្ស៊ីមណ្ឌលកំពង់ស្ពឺ លោក*នុត រំដួល* ក៏ធ្លាប់បាន ផ្តល់រហស្សនាមឱ្យថា ជាមេបញ្ជាការកងពល៩១១នោះនឹងមិនញញើតបញ្ជាទាហានឱ្យបាញ់ប្រជាពលរដ្ឋស្លូតត្រង់រឿងទំនាស់ដីធ្លីដូចមុនទៀតទេ ។

*យាយផាន* ដែលមានប្រវត្តិខាងបញ្ជាទាហាន អោយបាញ់ប្រជាពលរដ្ឋ ចាប់ប្រជាពលរដ្ឋ និងដុតបំផ្លាញ លំនៅឋានប្រជាពលរដ្ឋ នាពេលកន្លងមក ក៏កាន់តែមានអំណាចខ្លាំង នៅក្នុងរដ្ឋាភិបាលអាណត្តិទី៤ ក្នុងការធ្វើបាប ប្រជាពលរដ្ឋទៀតដែរ ។

ចំណែកឯច្បាប់ ប្រឆាំងនឹងអំពើពុករលួយវិញ នឹងត្រូវគេពន្យារពេល រយៈពេលចំនួន៥ឆ្នាំទៀត ព្រោះរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនខ្លាចណាស់ច្បាប់ ប្រឆាំងអំពើពុករលួយ ព្រោះបើមានច្បាប់ប្រឆាំងអំពើពុករលួយ វាដូចធ្វើគុកដាក់ខ្លួនពួកគេដែរ ។

លោក*ហ៊ុន សែន* នៃគណបក្សប្រជាជន នឹងមិនឱ្យច្បាប់ប្រឆាំងអំពើពុករលួយចេញរួចនៅក្នុងអាណត្តិថ្មីនេះទេហើយពួកគេ ក៏មានឱកាសតម្លើងថ្លៃប្រេងសាំងតាមអំពើចិត្ត ដូចដែលពួកគេ ធ្លាប់បានតម្លើងនាពេលកន្លងមកដែរ ។ មន្ត្រីគណបក្សប្រជាជន មានសិទ្ធិលក់ដីកោះ ភ្នំ បឹង ទន្លេ...ឱ្យឈ្មួញបរទេសដូចមុនទៀតដោយពួកគេគ្រាន់តែ ចំណាយប្រាក់ទិញសារុង ចែកប្រជាពលរដ្ឋម្នាក់មួយនៅជិតដល់ពេលបោះឆ្នោតម្តងៗ, ហើយបើប្រជាពលរដ្ឋណា ដែលគេទិញទឹកចិត្តមិនបាន និងដឹងថា មិនបោះឆ្នោតឱ្យពួកគេនោះ នឹងត្រូវគេលុបឈ្មោះចេញ ពីបញ្ជីបោះឆ្នោត ដូចការបោះឆ្នោតជាតិ កាលពីថ្ងៃអាទិត្យ ទី២៧ ខែកក្កដា កន្លងទៅនេះ ។

លទ្ធផល នៃការបន្លំសន្លឹកឆ្នោតនេះ ក៏បើកឱកាសអោយក្រុមឃាតកមានម្ចាស់ ធ្វើបាបជនស្លូតត្រង់ ដូចជាតារាភាពយន្ត និងអ្នកនយោបាយ បានតាមចិត្ត រយៈពេល៥ឆ្នាំទៀត ជាពិសេស កូនក្មួយលោក*ហ៊ុន សែន*ដែលតែងតែអាងអំណាចមាមីង ឪពុកម្តាយ ធ្វើផ្តេសផ្តាសតាមចិត្ត ។

លទ្ធផល នៃការលួចបន្លំសន្លឹកឆ្នោតនេះធ្វើ ឱ្យសមាជិកសែស្រឡាយអ្នក លួចជាតិ បក្ខពួកលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* អាចបន្តបទ ឧក្រិដ្ឋកម្មព្រៃឈើ របស់ខ្លួន នៅតំបន់ព្រៃឡង់និងឃុំទីរ៉ងស្រុកសណ្តាន់ខេត្តកំពង់ធំដូចរយៈពេល៥ឆ្នាំមុនទៀត។

លទ្ធផល នៃការលួចបន្លំសន្លឹកឆ្នោតនេះធ្វើឱ្យមន្ត្រីពុករលួយខ្មែរកេងប្រវ័ញ្ចប្រាក់ពន្ធរាប់រយលានដុល្លារក្នុងមួយឆ្នាំៗ និងបន្តតម្លើងថ្លៃទំនិញសព្វសារពើទៀតនិងមិន តម្លើងប្រាក់ខែឱ្យមន្ត្រីរាជការប៉ូលិស ទាហាន អាចរស់ បានរយៈពេល៥ឆ្នាំទៀត ។

ដូច្នេះរដ្ឋាភិបាល អាណត្តិទី៤ដែលកើតចេញពីលទ្ធផលនៃការលួចបន្លំសន្លឹកឆ្នោត កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨នេះ នឹងផ្តល់លទ្ធភាពអោយមន្ត្រីពុករលួយគណបក្សប្រជាជន ធ្វើអ្វីៗបានគ្រប់យ៉ាងដូចមុនដដែល ហើយនឹងបន្តធ្វើបាប ប្រជាពលរដ្ឋលើសមុនទៀត ដោយពួកគេនិយាយថា ប្រជាពលរដ្ឋគាំទ្រឱ្យពួកគេធ្វើដូច្នេះ ព្រោះប្រជាពលរដ្ឋជាអ្នកបោះឆ្នោតឱ្យពួកគេ កាន់អំណាចបន្តទៀត ។

សរុបសេចក្តីមក លទ្ធផលនៃការលួចបន្លំសន្លឹកឆ្នោត នេះ វាដូចពន្យារពេល ឱ្យអំពើពុករលួយរាតត្បាតប្រទេសកម្ពុជារយៈពេល៥ឆ្នាំទៀតដែរ ហើយមេឈ្មួញដែលមានឈ្មោះមិនល្អ*យាយផាន*និង អ្នកស្រី*យូ អយ* ក៏មានឱកាសធ្វើបាបរាស្ត្រដូច៥ឆ្នាំមុនទៀតដែរ ៕

**តមកពីទំព័រ៤ ខ**

សម្គាល់នោះគឺនៅពេលទាហានសៀមរំលោភឈ្លានពានចូលកាន់កាប់ដីខ្មែរនៅប្រាសាទតាក្របីនោះ ទាហានខ្មែរបានព្យាយាមរុញច្រានទាហានសៀមមិនឱ្យចូលព្រមទាំងបាញ់កាំភ្លើងមួយគ្រាប់ឡើងលើជាការព្រមាន ប៉ុន្តែទាហានសៀមនៅតែព្រហើនមិនខ្លាច ហើយរំលោភរុលចូលមកក្នុងប្រាសាទតាក្របីខ្មែរបានសម្រេចតាមបំណងរបស់ខ្លួន។

នេះក៏ដោយសារតែមានបញ្ជាពីថ្នាក់លើមិនឱ្យប៉ះពាល់ដល់ទាហានសៀមដូច្នេះទាហានសៀមក៏បានចិត្តតាំងតែពីរឿងសៀមចូលឈ្លានពានចូលវត្តកែវសិក្ខាគីរីស្វារៈ នៃតំបន់ប្រាសាទព្រះវិហាររបស់ខ្មែររហូតដល់ការបំពានចូលនៃទាហានសៀមកាន់កាប់ប្រាសាទតាមាន់ធំក្នុងខេត្តឧត្តរមានជ័យរបស់ខ្មែរទៀតនោះ។

មេបញ្ជាការកងវរសេនាតូចការពារព្រំដែន៤២២ *ហូ វុទ្ធី* បាននិយាយបញ្ជាក់ថា ទាហានខ្មែរយល់ព្រមដកកងទ័ពខ្មែរចេញពីប្រាសាទតាក្របីដែលខ្មែរធ្លាប់បានកាន់កាប់ឈរជើងប្រចាំការនៅទីនោះ បែបនេះដើម្បីឱ្យទាហានសៀមដែលចូលទើបចូលមកប្រាសាទខ្មែរនោះព្រមដកថយចេញទៅវិញ។

ដោយប្រាកដទៅ នេះគឺជាបញ្ជាពីថ្នាក់លើដែលមិនឱ្យមានការធ្វើអ្វីប៉ះពាល់ដល់កងទាហានសៀមឈ្លានពាន ជាពិសេសដើម្បីបញ្ចៀសការវាយប្រយុទ្ធគ្នាដែលអាចកើតមានឡើងជាយថាហេតុពីភាពគឃ្លើនរបស់ពួកទាហានសៀម ។ប៉ុន្តែនយោបាយបែបនេះក៏ទៅជាបង្ហាញឱ្យឃើញថាមេដឹកនាំខ្មែរបង្រៀនខ្មែរឱ្យខ្លាចសៀម សូម្បីតែដឹងថា សៀម បានគឃ្លើនឈ្លានពានកាន់កាប់ដីខ្មែរទាំងកម្រោលបំផុតនោះ។

ពិតមែនហើយ វាដូចជាសមរម្យម្យ៉ាងដែរ ពេលបានស្តាប់ឮនាយករដ្ឋមន្ត្រីកម្ពុជាលោក*ហ៊ុន សែន*និងរដ្ឋាភិបាលគណបក្សប្រជាជនលើកហេតុផលនិយាយអំពីរបស់ដែលហៅថា បញ្ចៀសការវាយប្រយុទ្ធបង្ហូរឈាមគ្នា ហើយងាកទៅប្រើវិធីចរចាផ្នែកការទូតដើម្បីបញ្ចប់បញ្ហានោះ។ ប៉ុន្តែកុំភ្លេចថា ដោយសារតែកំហុសនយោបាយបែបនេះដែលខ្មែរមិនហ៊ានទាំងប្រើប្រាស់អំណាចសិទ្ធិលើអធិបតេយ្យភាពនៃដែនដីរបស់ខ្លួនទប់ទល់នឹងការឈ្លានរបស់ទាហានសៀមនោះហើយដែលធ្វើឱ្យពួកទាហានសៀមចេះតែហ៊ានបន្តបំពានរំលោភចូលមកលើដីខ្មែរនៅចំពោះមុខទាហានខ្មែរនៅទីនោះ។

មើលចុះរបស់ដែលហៅថាការចរចាទ្វេភាគីផ្នែកការទូតក្នុងទិសដៅបញ្ចប់ជម្លោះប្រឈមមុខផ្នែកអាវុធនៅតំបន់ព្រំដែនខ្មែរ-សៀមពុំឃើញចេញលទ្ធផលជាអ្វីឱ្យច្បាស់ថាកម្ពុជាមិនខាតបាត់បង់ទឹកដីរបស់ខ្លួននោះទេ។ ក្នុងស្ថានភាពបែបនេះដែរគឺពួកសៀមជាអ្នកបានចំណេញគ្រប់បែបយ៉ាង ជាពិសេសការបន្តចូលកាន់កាប់ទឹកដីខ្មែរដោយហេតុផលពីរយ៉ាង បើខ្មែរបានជោគជ័យក្នុងការបណ្តេញពួកគេទៅវិញដោយផ្លូវណាមួយនោះក៏ពួកគេមិនខាតបង់ និងម្យ៉ាងទៀតបើខ្មែរមិនអាចដេញឬធ្វើអ្វីឱ្យពួកគេដកថយទៅវិញបាននោះគឺសៀមជាអ្នកចំណេញ។

បែបនេះហើយដែលបណ្ឌិត*រស់ ចន្ទ្រាបុត្រ* អនុប្រធានរាជបណ្ឌិតសភាកម្ពុជាដែលជាអ្នកវិទ្យាសាស្ត្រនយោបាយបានអធិប្បាយថាសៀមជាអ្នកចំណេញតែរហូត និងមិនមែនជាអ្នកខាតនោះទេក្នុងការលើកទាហានចូលកាន់កាប់ដីខ្មែរតាមតំបន់ព្រំដែននោះ។ ចំពោះបញ្ហានេះលោកបណ្ឌិតផ្តល់អនុសាសន៍ថាមានតែមេដឹកនាំកម្ពុជាយកបញ្ហានេះទៅប្តឹងទៅដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឱ្យគេប្រញាប់ចាត់ការជាបន្ទាន់ បញ្ចប់ការរំលោភឈ្លានពានរបស់ទាហានសៀម ។

ក្នុងយោបល់ស្របគ្នាដែរនោះលោក *ស៊ាន ប៉េងសែ*ដែលធ្លាប់បានគូសវាស់ផែនទីនៃទឹកដីកម្ពុជាហើយក៏ជាប្រធានគណៈកម្មការព្រំដែនកម្ពុជាមានមូលដ្ឋានធំនៅប្រទេសបារាំង និងធ្វើសកម្មភាពតាមបណ្តាប្រទេសនានានោះ លោកបានឱ្យយោបល់ថា ផ្លូវតែមួយដែលធ្វើឱ្យកម្ពុជាមិនខាតបាត់បង់ទឹកដីខ្មែរតាមបណ្តោយព្រំដែនទៅក្នុងដៃសៀមនោះមានតែការប្រញាប់ប្តឹងសៀមទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

ពួកអ្នកសង្កេតការណ៍ និងសកម្មជនការពារព្រំដែន ក៏ដូចជាមជ្ឈដ្ឋានអ្នកច្បាប់ និងអ្នកចេះដឹងខ្មែរទូទៅយល់ដូចគ្នាថាបើនៅក្នុងមជ្ឈដ្ឋាននិន្នាការផ្សេងៗគ្នានោះថា សៀមអនុវត្តន៍យុទ្ធសាស្ត្រការទូតដើម្បីអូសបន្លាយពេលវេលាឱ្យបញ្ហាក្លាយទៅជាត្រាំត្រែង ដូច្នេះទាហានសៀមអាចនឹងបន្តកាន់កាប់ទឹកដីខ្មែរកាន់តែយូរ រឹតតែល្អសម្រាប់សៀម ហើយជាផលចំណេញសម្រាប់សៀម។

ផែនការផ្នែកការទូតរបស់សៀមនោះគឺធ្វើឱ្យពិភពលោកមើលឃើញថាការដែលទាហានសៀមចូលកាន់កាប់ទឹកដីកម្ពុជានោះ ពុំមែនជាការប្រឈមមុខដាក់គ្នាផ្នែកយោធាដ៏ក្តៅគគុកគួរឱ្យព្រួយបារម្ភផ្នែកសន្តិសុខឬផ្ទុះសង្គ្រាមនោះឡើយ។ គឺបែបនេះហើយដែលសៀមចង់បង្ហាញថាខ្មែរពុំមានប្រតិកម្មអ្វីឱ្យធំដុំដោយហេតុថាទឹកដីដែលទាហានសៀមកាន់កាប់នោះ គឺជារបស់សៀម។

នេះគឺជាផ្នែកដ៏ធំសំខាន់នៃយុទ្ធសាស្ត្ររបស់សៀមការវាតទឹកដីដោយប្រើកម្លាំងយោធាឱ្យរំលោភបំពានចូលឱ្យធ្វើជាសុំចរចាជាទ្វេភាគីដោយសន្តិវិធី។ គឺការរុញបញ្ហាទៅឱ្យផ្នែកការទូតជួបជជែកគ្នានៅតុចរចារវាងភាគីខ្មែរ-សៀម មិនឱ្យភាគីអន្តរជាតិណាចូលរួមដឹងឮឡើយ។ ហើយទន្ទឹមនឹងនេះទាហានសៀមក៏បន្តធ្វើអ្វីៗបែបនេះជាហូរហែរហូតទៅដើម្បីឆ្លៀតកេងប្រវ័ញ្ចរកផលចំណេញពីលើភាពទន់ជ្រាយនៃមេដឹកនាំខ្មែរបច្ចុប្បន្នពោលគឺ គណបក្សប្រជាជន *ហ៊ុន សែន* ។

ពួកមេទាហានសៀមដែលកំពុងមានបញ្ហាមានទាំង*សាម៉ាក់ ស៊ុនដារ៉ាវេត* ក៏បានឆ្លៀតប្រើយុទ្ធសាស្ត្រដែលឱ្យមានការចរចាផ្នែករដ្ឋមន្ត្រីការបរទេសដែលតំណាងគ្នានោះ ខ្លួនឯងក៏បាននាំមេទាហានឱ្យចូលទៅមើលទឹកដីដែលទាហានរបស់ខ្លួនកំពុងចូលកាន់កាប់នោះ។

ជាពិសេសនោះមេទ័ពសៀមធំៗក៏បាននាំសេនានុព័ន្ធយោធាអមស្ថានទូតប្រចាំនៅទីក្រុងបាងកកនៃប្រទេសនានាឱ្យតាមខ្លួនទៅពិនិត្យមើលទឹកដីដែលទាហានរបស់ខ្លួនកំពុងកាន់កាប់ជារបៀបដើម្បីធ្វើការផ្សព្វផ្សាយបំភ័ន្តថា នោះគឺជាទឹកដីរបស់សៀម។

មកដល់ពេលនេះបើទោះបីជា *សាម៉ាក់ ស៊ុនដារ៉ាវេត* កំពុងមានបញ្ហាជាមួយផ្ទៃក្នុងនៅទីក្រុងបាងកកក៏ដោយក៏នាយករដ្ឋមន្ត្រីសៀមរូបនេះធ្លាប់បានឆ្លៀតចូលមកជួបទាហានសៀមដែលកំពុងកាន់កាប់ដីខ្មែរតាំងពីប្រាសាទតាមាន់ធំជាហូរហែដល់ប្រាសាទព្រះវិហារទៀត។

ចំណែកឯនាយករដ្ឋមន្ត្រីកម្ពុជាដែលជាម្ចាស់ទឹកដីមិនដែលហ៊ានអើតមុខទៅមើលទាហានខ្មែរដែលឈរជើងនៅតំបន់នោះឡើយ ក្រៅតែពីការស្រែកអួតក្អេងក្អាងពីទីក្រុងភ្នំពេញ ចង្អុលយ៉ាងនេះ ចង្អុលយ៉ាងនោះឱ្យគេធ្វើតាមដោយមិនដឹងថា នយោបាយរបស់ខ្លួនជាការចាញ់បោកល្បិចសៀមនៅលើគោកផងទេ៕

# ហែកដីឧទ្យានជាតិព្រះសីហនុរាមចែកគ្នាអស់ហើយ

**ដោយ : ជ.ឧត្តម**

គិតទៅរដ្ឋាភិបាលក្រុងភ្នំពេញដែលដឹកនាំដោយលោក *ហ៊ុន សែន* ពិតជាចម្លែកមែនទែនខណៈពេលដែលច្បាប់កំពុងស្ថិតនៅជាធរមានហើយនោះស្រាប់តែរដ្ឋាភិបាលមួយនេះបែរជាឆ្លៀតឱកាសចេញ ស.ជ.ណ ឬអនុក្រឹត្យជាន់ពីលើច្បាប់ថែមទៀតដែលធ្វើឱ្យច្បាប់នៅស្រុកខ្មែរមានជំងឺហើមស្រកៗរហូតមកដល់សព្វថ្ងៃ។

យ៉ាងណាមិញបញ្ហាដីឧទ្យានជាតិរាមដែលស្ថិតនៅក្នុងភូមិបត់គគីរសង្កាត់អូរឧកញ៉ាហេងខណ្ឌព្រៃនប់ ក្រុងព្រះសីហនុនិងកំពុងគ្រប់គ្រងដោយផ្នែកបរិស្ថាននោះ គឺមាន ស.ជ.ណពុះហែកចែកឱ្យអ្នកនេះ ឬអ្នកនោះអស់ទៅហើយ។ ហើយសូម្បីតែដីសហគមន៍កសិករដែលមានទំហំជាង១១០ហិកតា ក៏ត្រូវពួកខិលខូចអាងខ្នងប្រពន្ធអ្នកធំកេងពីប្រជាកសិករយកទៅធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនដែរ។

យោងតាមហេតុផលនេះហើយទើបប្រជាពលរដ្ឋប្រមាណ១៣៥គ្រួសារនៅសហគមន៍កសិករ ភូមិបត់គគីរ បាននាំគ្នាផ្តិតមេដៃលើពាក្យបណ្តឹងតវ៉ាទាមទារយកដីសហគមន៍ប្រមាណ១១០ហិកតា ដែលនៅក្បែរលំនៅដ្ឋានពួកគាត់មករក្សាទុកជាទ្រព្យសម្បត្តិរួមវិញ បន្ទាប់ពីប្រជាកសិករទាំងនោះដឹងថាមានការឃុបឃិតគ្នារវាងអាជ្ញាធរដែនដី និងមេសហគមន៍លួចលក់ដីនោះឱ្យឈ្មួញកន្លងមក។

ខ្លឹមសារនៃពាក្យបណ្តឹងនោះបានបង្ហាញឱ្យឃើញថា ដីសហគមន៍កសិករត្រូវបានគេបំប្លែងក្លាយជាដីឯកជនអស់ទៅហើយ ដែលការធ្វើបែបនេះ គឺជាអំពើខុសច្បាប់ទាំងស្រុង ព្រោះដីឧទ្យានជាតិរាមស្ថិតនៅក្នុងតំបន់ការពារដោយរដ្ឋមិនមែនចេះតែចេញ ស.ជ.ណចាត់ចែងចែកចាយស្រេចតែអំពើចិត្តអ្នកធំ រស់ក្រោមក្លៀកលោក*ហ៊ុន សែន* នោះទេ។

យោងតាមលក្ខន្តិកៈរបស់សហគមន៍បត់គគីរ ដែលបង្កើតឡើងដោយគំនិតផ្តួចផ្តើមរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថានគឺមានគោលបំណងសំខាន់ដើម្បីការពារដីព្រៃស្មាច់លិចទឹកចំនួន១១០ហិកតា។

ពេលនោះប្រជាពលរដ្ឋក្នុងសហគមន៍បានរួមគ្នាការពារយ៉ាងសស្រាក់សស្រាំដោយទាញយកផលប្រយោជន៍យ៉ាងច្រើនសម្រាប់បម្រើសហគមន៍វិញដូចជាអុសដុត, ដកផ្សិតធ្វើបន្លែនិងម្ហូបអាហារប្រចាំថ្ងៃទៀតផង។

ក្រោយមកដោយសារមេសហគមន៍ត្រូវដងត្រូវផ្លែជាមួយពួកឈ្មួញដី និងអាជ្ញាធរដែនដីមួយចំនួន គឺគេបានឃុបឃិតគ្នាលួចលក់បន្តិចម្តងៗដោយស្ងាត់ៗ។ ហើយទើបតែនៅឆ្នាំ២០០៦ និងឆ្នាំ២០០៨នេះទេស្រាប់តែលេចមុខឈ្មួញគ្រាក់ៗមកអះអាងយ៉ាងគឃ្លើនថា ដីសហគមន៍កសិករដែលជាដីឧទ្យានជាតិរាមនេះ ជាដីកម្មសិទ្ធិរបស់ពួកគេ។

នៅក្នុងពាក្យបណ្តឹងនោះប្រជាសហគមន៍ទាំង១៣៥គ្រួសារបានសំណូមពរដល់ប្រធានបរិស្ថានឧទ្យានជាតិរាមឱ្យជួយអន្តរាគមន៍ទាមទារដីទំហំ១១០ហិកតានោះមករក្សាទុកជាដីឧទ្យានជាតិនិងគ្រប់គ្រងដោយសហគមន៍វិញពិសេសគឺសុំបោះឆ្នោតជ្រើសរើសមេសហគមន៍ថ្មីនិងកំណត់ព្រំដីរបស់សហគមន៍ឱ្យបានច្បាស់លាស់។

តាមការអះអាងរបស់ប្រជាពលរដ្ឋបានឱ្យដឹងថា កាលពីអំឡុងឆ្នាំ១៩៩៣អាជ្ញាធរដែនដីបានឃុបឃិតគ្នាយកដីនេះលក់ឱ្យឧកញ៉ា *ជា សឿន* ម្តងរួចទៅហើយ តែក្រោយមកទើបរដ្ឋាភិបាលដកហូតដីនោះដាក់ចូលក្នុងឧទ្យានជាតិរាមដោយនិរាករណ៍ប្លង់កម្មសិទ្ធិឯកជនថែមទៀតផង។

គេមិនដឹងថា ឧកញ៉ា *ជា សឿន* មានវិធីផ្ទេរផ្ទុរយ៉ាងណានោះទេ ស្រាប់តែចុងក្រោយនេះ ដីសហគមន៍របស់កសិករដែលស្ថិតក្នុងដែនឧទ្យានជាតិរាមត្រូវធ្លាក់មកក្នុងដៃប្រពន្ធលោក *ស្បោង សារ៉ាត* មេគណបក្សប្រជាជនប្រចាំក្រុងព្រះសីហនុទៅវិញ។

ឥឡូវនេះប្រធានបរិស្ថានឧទ្យានជាតិរាមបានសម្រេចថានឹងទទួលយកពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋទៅជូនថ្នាក់លើដើម្បីមានវិធានការតាមផ្លូវច្បាប់ហើយ៕

**សេវាទទួលទិញសម្ភារៈចាស់ៗ**

មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំគ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល។

-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា

-មានទទួលទិញក្នុងតម្លៃសមរម្យ

-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម

ទំនាក់ទំនងទូរស័ព្ទលេខ : **017 606 125**

**ក្រុមហ៊ុនភាពយន្ត ជនបទ**

**មានទទួលបញ្ចាំង ខ្សែភាពយន្តខ្នាតធំ ក្នុងពិធីផ្សេងៗ មានពន្លឺច្បាស់ ទំនាក់ទំនងតាមទូរស័ព្ទ**

**012 66 44 67**

**015 66 44 67**

Khmer Machas Srok News

ការិយាល័យនិពន្ធ

Tel : 012 969 832 , 012 850 690

Fax : 023 987 411

E-mail: kmsnews@gmail.com

www.kmsblog.wordpress.com

ផ្នែកផ្សាយពាណិជ្ជកម្ម

Tel: 012 850 690 , 017 360 678, 015 645 170

Tel: 012 850 690 / 017 360 678 , Fax: 023 987 411

### តមកពីទំព័រ១ ន

កាលពីថ្ងៃទី០២ កញ្ញា ២០០៨ បានរៀបរាប់ថា កាលពីថ្ងៃទី ៣០ ខែកក្កដា ២០០៨ កន្លងមកនេះ រដ្ឋសភាបានផ្ញើលិខិតមួយច្បាប់ ស្នើសុំក្រសួងមហាផ្ទៃឱ្យជួយបំភ្លឺ ករណីលោកនួន វុទ្ធី តំណាងរាស្ត្រមណ្ឌលកំពង់ចាម ប្តឹងពីឈ្មោះហ៊ុន តូ និងបក្ខពួក ដោយអះអាងថា អ្នកទាំងនោះបានវាយដំនិងរំលោភដកហូតប័ណ្ណ អភ័យឯកសិទ្ធិសភារបស់លោកនួន វុទ្ធី ។ តែរហូតមកដល់ពេលនេះមិនមានការឆ្លើយតបណាមួយពីក្រសួងមហាផ្ទៃឡើយ ។

លោកឡេង ប៉េងឡុង បានស្នើលោកស ខេង ជម្រុញការស្រាវជ្រាវករណីនេះ ហើយសូមមេត្តារាយការណ៍ មករដ្ឋសភាវិញដើម្បីរដ្ឋសភាប្រើការក្នុងការទំនាក់ទំនង ជាយថាហេតុ ជាមួយសហភាពអន្តរសភានៅទីក្រុង Genéve ។

គួរបញ្ជាក់ថា កាលពីវេលាម៉ោង២:២០នាទីរសៀល ថ្ងៃទី១៩ ខែកក្កដា ២០០៨ នៅពេលដែលលោកនួន វុទ្ធី កំពុងតែស្ថិតក្នុងរថយន្ត ជាមួយនឹងសហការី លើសាឡាងព្រែកក្តាម ឈ្មោះហ៊ុន តូ បានបញ្ជាឱ្យក្រុមអង្គរក្សរបស់ខ្លួន វាយដំលើរូបលោក(នួន វុទ្ធី) យ៉ាងដំណំ រហូតដល់រហែកអាវអស់ ហើយបានដកហូត យកប័ណ្ណអភ័យឯកសិទ្ធិសភា តំណាងរាស្ត្ររបស់លោកទៀតផង ។ បើទោះបីលោកនួន វុទ្ធី បានបង្ហាញប័ណ្ណ អភ័យឯកសិទ្ធិសភា ហើយបានប្រាប់បក្ខពួកលោកហ៊ុនតូថាជាអ្នកតំណាងរាស្ត្រហើយក៏ដោយ ។ នៅក្រោយពេល កើតហេតុភ្លាមៗ លោកនួន វុទ្ធី បានដាក់ពាក្យបណ្តឹងទៅអធិការ ស្រុកពញាឮ ហើយអធិការក៏បានធ្វើកំណត់ហេតុផងដែរ ។

លោកនួនវុទ្ធីបានប្តឹងលោកហ៊ុន តូ ទៅអង្គការសិទ្ធិមនុស្សអាដហុក ស្នងការអង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្សនៅកម្ពុជា ទៅរដ្ឋសភា និងតុលាការខេត្តកណ្តាលផងដែរ ។ ចំពោះបណ្តឹង ទៅតុលាការនោះ លោកនួន វុទ្ធី បានស្នើអោយតុលាការ ចាត់វិធានការទៅតាមបទល្មើសព្រហ្មទណ្ឌ និងស្នើឱ្យភាគីលោកហ៊ុន តូ សងជម្ងឺចិត្តចំនួន៨០លានរៀល ប្រហែល២ម៉ឺនដុល្លារ ។

នៅថ្ងៃទី២២សីហា ២០០៨ ព្រះរាជអាជ្ញាខេត្តកណ្តាលបានហៅលោកនួន វុទ្ធី ទៅសួរនាំរួចមក,ភាគីលោកហ៊ុន តូ បានដាក់ពាក្យបណ្តឹងប្តឹងលោកនួន វុទ្ធីវិញ ទារជម្ងឺចិត្តចំនួន២០០លានរៀល ប្រហែលនឹង៥ម៉ឺនដុល្លារអាមេរិក ពីបទបរិហារកេរ្តិ៍ ។

លោកនួន វុទ្ធី បានប្រាប់ខ្មែរម្ចាស់ស្រុក កាលពីព្រឹកម្សិលមិញ ពាក់ព័ន្ធនឹងលោកហ៊ុន តូ ប្តឹងបកវិញថា "ខ្ញុំយល់ឃើញថា ការទាមទាររបស់ឧកញ៉ាហ៊ុន តូនេះ វាគ្រាន់តែជាលេសមួយ ដើម្បីបំភ័ន្តតុលាការ ពីការស្រាវជ្រាវរឿងហ្នឹងទេ ពីព្រោះវាយមនុស្ស ទល់មុខគ្នា, ហើយខ្ញុំសំណើ ឱ្យលោកហ៊ុន តូ ឈប់វាយទល់មុខគ្នា សាក្សីដែលសូម្បីតែខ្ញុំមួយ គឺវាគ្រប់គ្រាន់ហើយ ព្រោះខ្ញុំជាតំណាងរាស្ត្រដែលត្រូវគេរំលោភយ៉ាងនេះ ។ យើងមានសាក្សីមួយទៀតជាសហការីខ្ញុំ" ។

នៅពេលដែលសួរថាបើសិនជាលោកស ខេង មិនចាត់ការតាមសំណើ របស់លោកឡេង ប៉េងឡុង ទេ តើលោកនឹងត្រូវធ្វើយ៉ាងម៉េច ដើម្បីទទួលបាននូវភាពយុត្តិធម៌នោះ ? លោកនួន វុទ្ធី បានថ្លែងថា "បើសិនជាក្រសួងមហាផ្ទៃ មិនព្រមចាត់វិធានការរឿងនេះទេមានន័យថា រដ្ឋាភិបាលមិនទទួលខុសត្រូវ លើសិទ្ធិប្រជាពលរដ្ឋ សូម្បីតែតំណាងរាស្ត្រមួយ ជាតំណាងប្រជាពលរដ្ឋក៏មិនបានការពារ មិនបានស្រាវជ្រាវចុះ ប្រជាពលរដ្ឋធម្មតា នឹងជួបនូវការលំបាកមែនទែន" ។ អ្នកតំណាងរាស្ត្រនួន វុទ្ធី បានរំលឹកអំពីព្រឹត្តិការណ៍ នៃក្រុមបក្ខពួករបស់លោកហ៊ុន តូ វាយដំថា "រឿងនោះវាគ្រាន់តែកើតមាននៅលើសាឡាងភ្លាម, ប្រជាពលរដ្ឋដែលបានឃើញហេតុការណ៍ហ្នឹង បាននិយាយប្រាប់ខ្ញុំថានេះលោកជាតំណាងរាស្ត្រ តែបើសិនជា ប្រជាពលរដ្ឋធម្មតាវិញ ប្រហែលជាពួកឧកញ៉ាហ៊ុន តូ ចាប់ខ្ញុំបោះទម្លាក់ទឹកទន្លេបាត់ហើយ ។ ប្រជាពលរដ្ឋ ជាអ្នកលក់ដូរ នៅលើសាឡាងនោះ តែងតែឃើញឧកញ៉ាហ៊ុន តូ និយមឆ្លងកាត់សាឡាងព្រែកក្តាមហ្នឹង" ។

លោកនួន វុទ្ធី ក៏បានពណ៌នាអំពីចរិតកោងកាច របស់ឧកញ៉ាហ៊ុន តូនាពេលកន្លងមក ថា "ខ្ញុំធ្លាប់ដឹងឮ តាមរយៈប្រជាពលរដ្ឋនៅលើសាឡាងហ្នឹងឯង, ហើយឮអ្នករត់តាក់ស៊ីអះអាងថា ពេលឧកញ៉ាហ៊ុន តូ ឆ្លងកាត់សាឡាងនោះ បើអ្នកធ្វើការបើកផ្លូវ មិនទាន់អោយគាត់ទេគាត់រករឿងហើយ" ។

គួរបញ្ជាក់ថាឧកញ៉ាហ៊ុន តូ ជាកូនប្រុសលោកហ៊ុន ណេង អភិបាលខេត្តកំពង់ចាម និងជាក្មួយប្រុសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។

ខ្មែរម្ចាស់ស្រុកមិនអាចទាក់ទងឧកញ៉ាហ៊ុន តូ ដើម្បីធ្វើការបំភ្លឺករណីនេះបានទេ កាលពីថ្ងៃម្សិលមិញ ៕

### តមកពីទំព័រ១ ម

ភ្ជាប់ជាមួយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញផងដែរ គឺមិនអនុញ្ញាត ឱ្យសមាជិកសភាគណបក្សសម រង្ស៊ី ធ្វើពិធីស្បថដាច់ដោយឡែកនោះទេ ។

ប៉ុន្តែសមាជិកសភាថ្មី របស់គណបក្សសម រង្ស៊ីទាំង២៦រូប បានប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់និងឆ្លើយតប ថ្វាយព្រះករុណាវិញជាលិខិត លាយល័ក្ខណ៍អក្សរថ្ងៃម្សិលមិញថា ពួកគេនៅតែរក្សាជំហរដដែល គឺមិនចូលរួមស្បថ ជាមួយអ្នកតំណាងរាស្ត្រចោរ តំណាងរាស្ត្រយួន និងតំណាងរាស្ត្រខ្មោច ដែលគ្រោងនឹងធ្វើដោយខុសច្បាប់ រដ្ឋធម្មនុញ្ញ ត្រង់មាត្រា៧៦ នៅថ្ងៃទី២៤ កញ្ញា ២០០៨ ។

ព្រះលិខិត របស់ព្រះមហាក្សត្រ កាលពីថ្ងៃទី១១ កញ្ញា ២០០៨ ផ្ញើជូនលោកសម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី បានរៀបរាប់ថា "ខ្ញុំបានទទួលរួចហើយ លិខិតរបស់ឯកឧត្តមចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការទូលស្នើសុំធ្វើពិធីសច្ចាប្រណិធានដោយឡែកក្នុងការចូលកាន់តំណែង តំណាងរាស្ត្រទើបជាប់ឆ្នោត នៃគណបក្សសម រង្ស៊ី ។ ខ្ញុំសូមផ្ញើច្បាប់ចម្លង លិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ០១៨/១៣/២០០៨ កបធ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨ ជូនឯកឧត្តមប្រធានគណបក្សសម រង្ស៊ី" ។

ខ្លឹមសារនៃលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលទូលថ្វាយព្រះមហាក្សត្រ មាន៤ចំណុចដូចតទៅ :

១-វាក្យខ័ណ្ឌទី១ មាត្រា៨២ថ្មីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាចែងថា "រដ្ឋសភា បើកសម័យប្រជុំដំបូងហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ" ។ យោងតាមវាក្យខ័ណ្ឌ ខាងលើនេះ ព្រះមហាក្សត្រ ទ្រង់កោះហៅបេក្ខជនជាប់ឆ្នោត ជាស្ថាពរទាំងអស់ ឱ្យចូលរដ្ឋសភាទទួលព្រះរាជសារ តាមពេលវេលាកំណត់ ។

២-ឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុញ្ញាត ឱ្យសមាជិករដ្ឋសភាធ្វើសច្ចាប្រណិធាន នៅចំពោះមុខព្រះភ័ក្ត្រ ព្រះមហាក្សត្រ ព្រះភ័ក្ត្រ សម្តេចព្រះសង្ឃរាជ និងទេវតារក្សាស្វេតច្ឆត្រ មិនមែនអនុញ្ញាត ឱ្យបេក្ខជនជាប់ឆ្នោតនោះទេ ។

៣-វាក្យខ័ណ្ឌ មាត្រា៧នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា "អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ" ។ អង្គព្រះមហាក្សត្រ មិនអាចបុគ្គលណាស្នើតម្រូវឱ្យព្រះអង្គ ទ្រង់ព្រះតម្រិះ តាមចំណង់ចំណូលចិត្តរបស់ខ្លួនបានឡើយ ។

៤-ព្រះមហាក្សត្រ ព្រះអង្គជានិមិត្តរូបនៃការបង្រួបបង្រួមជាតិ ទ្រង់មានតួនាទីដ៏ខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ក្នុងការធ្វើឱ្យអំណាចសាធារណៈបានប្រព្រឹត្តទៅជាប្រក្រតី ។

ទោះយ៉ាងណា អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ទើបជាប់ឆ្នោតថ្មីទាំង២៦រូប បានសរសេរលិខិតផ្លូវការទូលថ្វាយព្រះមហាក្សត្រ នៅថ្ងៃម្សិលមិញថា ពួកគេមិនចូលរួមស្បថជាមួយតំណាងរាស្ត្រចោរ តំណាងរាស្ត្រយួន និងតំណាងរាស្ត្រខ្មោច ដែលគ្រោងនឹងធ្វើនៅថ្ងៃទី២៤ កញ្ញា ២០០៨ នោះទេដោយសារតែសមាជិកសភា តំណាងអោយអ្នកគាំទ្រជាងមួយលាននាក់ និងប្រជាពលរដ្ឋ រាប់លាននាក់ទៀតមិនទទួលបានយុត្តិធម៌ នៅក្នុងការបោះឆ្នោត កាលពីថ្ងៃទី២៧ខែកក្កដា ២០០៨កន្លងទៅនេះ។ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ទាំង២៦រូបនោះ បានធ្វើការកត់សំគាល់ថា ភាពអយុត្តិធម៌នៃការបោះឆ្នោតនេះ មិនត្រូវបានគេដោះស្រាយ ដើម្បីផ្តល់យុត្តិធម៌ ដល់ពលរដ្ឋខ្មែរ ដែលត្រូវគេលុបឈ្មោះ មិនឱ្យបោះឆ្នោតទេនោះ, មេដឹកនាំខ្មែរសព្វថ្ងៃ នឹងធ្វើឱ្យប្រទេសឈានទៅរកភាពផ្តាច់ការ ដឹកនាំរដ្ឋាភិបាល រដ្ឋសភានិងគ្រប់គ្រងកម្លាំងកងទ័ព ។

ពាក់ព័ន្ធនឹងលិខិត ឆ្លើយតបរបស់ព្រះមហាក្សត្រនេះ លោកសម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី បានផ្តល់បទសម្ភាសន៍ ឱ្យវិទ្យុបារាំងអន្តរជាតិ កាលពីយប់ថ្ងៃពុធថា ព្រះមហាក្សត្រគ្មានអំណាចទេ, ហើយព្រះអង្គសំរេចព្រះទ័យ ច្រើនតែទៅតាមអ្វីដែលគណបក្សប្រជាជនចង់បាន ។

ក្រុមអ្នកច្បាប់ បានកោតសរសើរ ភាពរឹងមាំរបស់សមាជិកសភា គណបក្សសម រង្ស៊ី ចំនួន២៦រូប និងអ្នកតំណាងរាស្ត្រ គណបក្សសិទ្ធិមនុស្ស៣រូប ដែលរក្សាជំហរ មិនព្រមចូលរួមស្បថ ជាមួយសមាជិកសភាចោរ សមាជិកសភាខ្មោច និងសមាជិកសភាយួន ដែលលោកសម រង្ស៊ី អះអាងថា មានជនជាតិយួន បោះឆ្នោតបាន, អ្នកខ្លះគ្មានសិទ្ធិទៅបោះឆ្នោតផង អាចប្រើឈ្មោះខ្មោចបោះឆ្នោត ជូនគណបក្សប្រជាជន ។

លោកគល់ បញ្ញា ប្រធានអង្គការខុមហ្វ្រែល បានថ្លែងប្រាប់វិទ្យុបរទេស ផ្សាយជាខេមរភាសា កាលពីពេលថ្មីៗនេះថាបើសិនជាសមាជិកសភាគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស សរុបទាំង២៩ មិនចូលរួមស្បថ នៅថ្ងៃដំបូងដែលគ្រោងធ្វើ នៅថ្ងៃទី២៤ ខែកញ្ញា ២០០៨ទេ នោះភាពរកាំរកូសនៅក្នុងរដ្ឋសភា រយៈពេល៥ឆ្នាំក្នុងអាណត្តិនេះ នឹងមានហើយ ។

ក្រុមអ្នកច្បាប់ បាននិយាយថា ការរក្សាជំហររបស់សមាជិកសភាគណបក្សប្រឆាំង មិនចូលរួមប្រជុំសភាដំបូងនេះ ជាសញ្ញាមួយបញ្ជាក់ថាជាការគោរព ឆន្ទៈរាស្ត្រពិតប្រាកដ និងការពាររដ្ឋធម្មនុញ្ញ របស់ប្រទេស ដែលជាច្បាប់កំពូល មិនឱ្យជនផ្តាច់ការ ប្រើប្រាស់ជាឧបករណ៍អំណាច របស់ពួកគេតទៅទៀត ៕

### តមកពីទំព័រ១ ខ

គ្នារំលោភចូលកាន់កាប់ប្រាសាទតាក្របី សូម្បីតែមានទាហានខ្មែរនៅទីនោះ ហើយដែលប្រាសាទនេះស្ថិតនៅចម្ងាយប្រមាណ ១៥គីឡូម៉ែត្រពីប្រាសាទតាមាន់ នៅក្នុងភូមិសាស្ត្រស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

ពួកទាហានសៀមអស់នេះក៏បានព្រមដកខ្លួនថយចេញទៅវិញនៅវេលារសៀលម៉ោង៣ នៃថ្ងៃទី១១ខែកញ្ញា ក្រោយពីមានការនិយាយដាក់លក្ខខណ្ឌគ្នាជាមួយទាហានខ្មែរ។ លក្ខខណ្ឌនោះគឺ ទាហានខ្មែរក៏ព្រមចេញពីប្រាសាទខ្មែរនោះដែរ ដូច្នេះទើបធ្វើឱ្យទាហានសៀមព្រមដកថយចេញពីទឹកដីខ្មែរ។

ហេតុការណ៍ដែលគួរឱ្យកត់

តទៅទំព័រ៣ ខ

### តមកពីទំព័រ១ ក

គណបក្សប្រជាជននោះ សហភាពអឺរ៉ុបនឹងចេញផ្សាយរបាយការណ៍របស់ខ្លួនដែលក្នុងនោះក៏មានទាក់ទិននឹងការវាយតម្លៃនៃលទ្ធផលនៃការបោះឆ្នោតនៅកម្ពុជាកាលចុងខែកក្កដាដែរ។

សម្រាប់ប្រជារាស្ត្រខ្មែរម្ចាស់សន្លឹកឆ្នោតនោះ ពិតជាចង់បានយ៉ាងច្បាស់នូវជំហរប្រកបដោយយុត្តិធម៌របស់រដ្ឋាភិបាលនានានៃសហគមន៍អឺរ៉ុបដើម្បីធានាថាដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាមិនត្រូវបំផ្លាញដោយអំណាចនៃកលល្បិចរបស់គណបក្សប្រជាជន ហ៊ុន សែន តាមរយៈ គ.ជ.ប និងអាជ្ញាធរដែនដីបំភ្លៃលទ្ធផលនៃការបោះឆ្នោតនោះទេ។គឺបែបនេះហើយ បានជាមានការតស៊ូព្យាយាមទាមទារឱ្យមានអន្តរាគមន៍ពីបណ្តាប្រទេសម្ចាស់ជំនួយដើម្បីធានាថា ពីពេលនេះតទៅមុខដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាមិនអាចបណ្តោយឱ្យធ្លាក់ចូលទៅក្នុងគ្រោះនៃការគំរាមកំហែងដោយអំណាចផ្តាច់ការ ផ្តាច់មុខរបស់គណបក្សប្រជាជន ហ៊ុន សែន នោះ។

លោក សម រង្ស៊ី រួមដំណើរដោយលោក កឹម សុខា កំពុងបន្តយុទ្ធនាការតវ៉ានៅសហភាពអឺរ៉ុប ជាសហគមន៍នៃបណ្តាប្រទេសចំនួន២៧ដែលក៏បានបញ្ជូនអ្នកសង្កេតការណ៍របស់ខ្លួនឱ្យតាមឃ្លាំពិនិត្យមើលដំណើរការនៃការបោះឆ្នោតនៅកម្ពុជានោះដែរ។ ហើយមកដល់ពេលនេះ សហភាពអឺរ៉ុបនៅមិនទាន់ចេញផ្សាយអ្វីជារបាយការណ៍បញ្ជាក់នូវជំហរផ្លូវការរបស់ខ្លួនទាក់ទិននឹងការបោះឆ្នោតនៅកម្ពុជានេះទេ។

លោក សម រង្ស៊ី ប្រធាននៃគណបក្សប្រឆាំងបានពិពណ៌នាកាលពីពេលថ្មីៗនេះថា សហភាពអឺរ៉ុប ក៏ដូចជាប្រទេសបារាំងមិនទាន់ចេញរបាយការណ៍ទទួលស្គាល់ការបោះឆ្នោតនៅកម្ពុជាថាត្រឹមត្រូវនោះឡើយ។ គេត្រូវរង់ចាំនូវការប្រមូលបានទិន្នន័យ និងព័ត៌មាននានាដើម្បីធ្វើការវាយតម្លៃ ហើយចេញរបាយការណ៍ឈរលើការវិភាគមូលដ្ឋានច្បាស់លាស់ឱ្យមានយុត្តិធម៌ ជាការធានាថា លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាមិនអាចរងការបំផ្លាញដោយនយោបាយរបស់គណបក្សប្រជាជន ហ៊ុន សែន នោះ។

អ្នកសង្កេតការណ៍ពីសហគមន៍អឺរ៉ុបមិនទាន់ទទួលស្គាល់ថាការបោះឆ្នោតនៅកម្ពុជាកន្លងទៅមានលក្ខណៈតាមស្តង់ដារអន្តរជាតិនោះទេ ដែលការបោះឆ្នោតនេះជាឱកាសឱ្យគណបក្សប្រជាជន ហ៊ុន សែន ប្រើប្រាស់ គ.ជ.ប ជាឧបករណ៍របស់ខ្លួន និងអាជ្ញាធរដែនដីបំភ្លៃលួចបន្លំ និងបំភ័ន្តប្រជារាស្ត្រ ក៏ដូចជាប្រកាសបំប៉ោងលទ្ធផលឱ្យខ្លួនបានអាសនៈសភាដល់ទៅ៩០ ហួសពីចំនួននៃសម្លេងដែលប្រជារាស្ត្រខ្មែរពិតប្រាកដបោះឆ្នោតឱ្យគណបក្សប្រជាជននោះ។

សហភាពអឺរ៉ុបដែលក៏ជាម្ចាស់ជំនួយដ៏សំខាន់សម្រាប់ការស្តារ និងអភិវឌ្ឍន៍កម្ពុជាឡើងវិញមានតួនាទីសំខាន់ផងដែរ ដូចមានចែងក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីស ២៣ តុលា ១៩៩១ ដែលនិយាយអំពីហត្ថលេខីទាំងឡាយ ធានាឱ្យមានដំណើរការប្រជាធិបតេយ្យនៅកម្ពុជា ដូចជាតាមរយៈការបោះឆ្នោតត្រឹមត្រូវ យុត្តិធម៌ សេរី។ ដូច្នេះការទទួលខុសត្រូវរបស់សហភាពអឺរ៉ុបចំពោះដំណើរការប្រជាធិបតេយ្យនៅកម្ពុជា គឺជារឿងដ៏ ធំសំខាន់ និងចាំបាច់។ យ៉ាងនេះហើយ បានជាលោក សម រង្ស៊ី រួមដំណើរដោយលោក កឹម សុខា បានធ្វើយុទ្ធនាការ តវ៉ាប្រឆាំងឱ្យមានអន្តរាគមន៍របស់សហភាពអឺរ៉ុបនោះ។

ដោយសារគណបក្សប្រជាជន ហ៊ុន សែន បានសម្រេចផែនការក្នុងការលួចសន្លឹកឆ្នោត ប្តូរសន្លឹកឆ្នោត បំប៉ោងសន្លឹកឆ្នោតនិងបំភ្លៃលទ្ធផលនៃការបោះឆ្នោតឱ្យខ្លួនដែលមាន គ.ជ.ប ជាឧបករណ៍ប្រកាសថា គណបក្សប្រជាជនបានអាសនៈសភាដល់ទៅ៩០នោះ រឿងនេះជាសញ្ញានៃការគំរាមកំហែងដល់ដំណើរការប្រជាធិបតេយ្យនៅកម្ពុជា ដូចការកង្វល់របស់អង្គការសង្គមស៊ីវិល។ បែបនេះហើយ បានជាសហគមន៍អន្តរជាតិទាំងសហភាពអឺរ៉ុប និងអាមេរិកមានភារកិច្ចជាចាំបាច់ត្រូវតែទប់ស្កាត់ឱ្យខាងតែបានជាមុននូវដំណើរកម្ពុជាធ្លាក់ទៅក្នុងប្រភេទប្រព័ន្ធរបបផ្តាច់ការក្រោមអំណាចដឹកនាំរបស់គណបក្សប្រជាជន ហ៊ុន សែន តាមគំរូនៃប្រទេសយោធាផ្តាច់ការភូមានោះ។

រាស្ត្រខ្មែរសង្ឃឹមថា របាយការណ៍របស់សហភាពអឺរ៉ុបនឹងថ្កោលទោសអំពើលួចបន្លំប្តូរសន្លឹកឆ្នោត និងបំភ្លៃលទ្ធផលនៃការបោះឆ្នោតប្រព្រឹត្តកេងយកចំណេញដោយគណបក្សប្រជាជន ហ៊ុន សែន ដើម្បីបញ្ឈប់វប្បធម៌នៃការបំផ្លាញលទ្ធិប្រជាធិបតេយ្យដ៏ក្មេងខ្ចីនៅកម្ពុជា៕